# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការធ្វើអនុបយោគផ្ទៃដីទំហំ ៩.០១៨ ហិកតា មានទីតាំងស្ថិត នៅក្នុងឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.០១៤ ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដើម្បីធ្វើការវិនិយោគដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ ៤០៤ អនញ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១ របស់សាលាខេត្តមណ្ឌលគិរី ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

## ផែនទី ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ប៉ាស៊ីហ្វិក ឡូធើស យ៉ីនស្តុក ខមផេនីលីមីធីត
## (PACIFIC LOTUS JOINT-STOCK COMPANY LIMITED)
## ស្ថិតនៅក្នុង ឃុំយ៉េ ស្រុកកោះញែក ខេត្តមណ្ឌលគិរី




សញ្ញាសំគាល់ :

- ព្រំប្រទល់ដីស្នើសុំ
- ព្រំប្រទល់ខេត្ត
- ផ្លូវជាតិថ្មី
- ផ្លូវទឹក
- ដីជាន់ជាមួយវារីអគ្គិសនី
- ព្រៃការពារប្រភពទឹក
- ព្រៃការពារទីជម្រាល
- ដីតាមបណ្ដោយខាងផ្លូវ
- ដីស្រែ
- ភ្នំ-ស្រែ

ចំណាត់ថ្នាក់ព្រៃឆ្នាំ២០០២ក្នុងតំបន់ដីមិនកាត់ចេញ :

| | |
|---|---|
| ព្រៃស្រោង | ២ ១៤០ ហ.ត |
| ព្រៃពាក់កណ្ដាលស្រោង | ៧០៨ ហ.ត |
| ព្រៃល្បោះ | ៥ ៧៤៣ ហ.ត |
| ព្រៃឬស្សីល្បាយ | ៤៧ ហ.ត |
| ដីគ្មានព្រៃ | ២៤៤ ហ.ត |
| សរុប : | ៩ ០១៤ ហ.ត |

ផ្ទៃដីស្នើសុំ: ១១ ៤៣០ ហ.ត

ផ្ទៃដីកាត់ចេញ :

| | |
|---|---|
| ព្រៃជាន់ជាមួយវារីអគ្គិសនី | ១ ១៣៨ ហ.ត |
| ព្រៃការពារប្រភពទឹក | ១ ១១០ ហ.ត |
| ព្រៃការពារទីជម្រាល | ៧០ ហ.ត |
| ដីតាមបណ្ដោយខាងផ្លូវ | ៣៨ ហ.ត |
| ដីស្រែ | ៦០ ហ.ត |
| ផ្ទៃដីកាត់ចេញសរុប : | ២ ៤១៦ ហ.ត |
| ផ្ទៃដីមិនកាត់ចេញ : | ៩ ០១៤ ហ.ត |

COORDINATE SYSTEM

| | |
|---|---|
| Projection: | UTM |
| Zone: | 48 |
| Horizontal Datum: | Indian 1960 |
| Spheroid: | Everest |
| UTM Grid: | 2 Km |

N W E S

មាត្រដ្ឋាន ១ : ១០០ ០០០

2 0 2 Km

លេខ...០៤៧/អ

បានឃើញ និង ឯកភាព

សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ពិនិត្យ និងសម្រេច

...ថ្ងៃទី...ខែ...ឆ្នាំ២០១១

ប៊ិល-ម៉ិច

លេខ...

បានឃើញ និង ឯកភាព

សូមគោរពជូនឯកឧត្តមអភិបាលខេត្តពិនិត្យ និងសម្រេច

...ថ្ងៃទី...ខែ...ឆ្នាំ២០១១

ធើស-ស៊ឿន

លេខ...

បានឃើញ និងឯកភាព

គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យ និងសម្រេច

...ថ្ងៃទី...ខែ...ឆ្នាំ២០១១

ចាន់-យឿន

លេខ...

បានឃើញ និង ឯកភាព

សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រីពិនិត្យ និងសម្រេច

...ថ្ងៃទី...ខែ...ឆ្នាំ២០១១

លេខ...

បានឃើញ និង ឯកភាព

សូមគោរពជូនឯកឧត្តមអភិបាលខេត្តមណ្ឌលគិរីពិនិត្យ និងសម្រេច

...ថ្ងៃទី...ខែ...ឆ្នាំ២០១១

ឈឹម-កាន